លី-ធាមតេង

# លោកនីតិ

B-15
D-34
N°64




...ជាតិ

ថ្នាក់ទី ៩

រោងពុម្ពរស្មី

# លោកនីតិ

សម្រាប់

ថ្នាក់ទី ៩ បឋមសិក្សា

# INSTRUCTION CIVIQUE

**Classe de 9ème**

សាធារណរដ្ឋប្រជាមានិតកម្ពុជា
លេខកូដ : ..........
លេខបញ្ជី : ..........

បោះពុម្ពលើកទី ១

រក្សាសិទ្ធិ

ព. ស. ២៥១០ គ. ស. ១៩៦៧

បណ្ណាគារ រោងពុម្ព រស្មី
១៤៧, មហាវិថី ហ្សាលដឺហ្គោលភ្នំពេញ

# អារម្ភកថា

បើពុំបានផាគិត គេច្រើនយល់ច្រឡំថា៖ ការសិក្សាលោកនីតិ ពុំសូវមានប្រយោជន៍អ្វីទេ ។ ព្រោះតែការយល់ខុសដូចនេះ វិជ្ជានេះ ក៏អស់សារៈ ដែលគេរៀនតែបន្តិចបន្តួច ឬរៀនឲ្យតែបានពេញម៉ោង ក្នុងតារាងចែកពេលតែប៉ុណ្ណោះ ។

តាមពិត វិជ្ជាលោកនីតិ ជាចាំបាច់ណាស់ សំរាប់ពលរដ្ឋទូទៅ បើយើងហៅឲ្យចំន័យថា "វិជ្ជាសំរាប់រៀនឲ្យមានលក្ខណៈ ជាពលរដ្ឋពេញលេញ" ដូច្នេះ ក៏បាន ។ ព្រោះថា ពលរដ្ឋម្នាក់ ៗ តែងរស់នៅក្រោមអំណាចច្បាប់ ក្នុងគ្រប់ខណ្ឌច្បាប់សំរាប់គ្រប់គ្រងប្រទេស; ឯវិជ្ជានេះ គឺជាក្បួនខ្នាត សំរាប់ពលរដ្ឋចេះដឹងរបៀបរបប ក្នុងការប្រតិបត្តិច្បាប់, ក្នុងរបបគ្រប់គ្រងស្រុកទេសនេះឯង ។

សិស្សានុសិស្សពិតមែនតែនៅតូចៗ ពុំទាន់ចាប់ក្នុងជីវភាពជាពលរដ្ឋមែន នៅវេលានេះ តែទៅអនាគត សិស្សទាំងនេះពេញវ័យឡើង នឹងបានជាពលរដ្ឋនៃប្រទេសពេញលក្ខណៈៗ ដូច្នេះ សិស្សានុសិស្សត្រូវតែចេះច្បាប់សំរាប់ខ្លួនជាមុន ឲ្យបានច្បាស់លាស់គឺវិជ្ជាដែលហៅថា "លោកនីតិ" នេះ ។

ហេតុនេះ ត្រូវទុកវិជ្ជានេះ ជាវិជ្ជាច្បងមួយដែរ ។

ភ្នំពេញ ថ្ងៃ ១៤ មេសា ១៩៦៣

លី - ធាមតេង

# សេចក្ដីណែនាំជាមុន

ការរៀបរៀងសៀវភៅនេះ សំអាងទាំងស្រុងទៅលើកម្មវិធីសិក្សា នៅបឋមភូមិ ដែលកំពុងអនុវត្តសព្វថ្ងៃ ។ យើងបានបែកមេរៀន ទៅតាមកម្មវិធី បែងក្នុងត្រីមាសទាំងបី គឺត្រីមាសណាត្រូវរៀនពីអ្វីខ្លះ យើងរៀបរៀងមេរៀន តម្រូវតាមនោះ ។ ប៉ុន្តែរបៀបរៀបរៀងជាមេរៀននេះ ពិបាកបន្តិច ព្រោះមេរៀនខ្លះមានន័យទូលំទូលាយណាស់ បើនិយាយឲ្យពិស្ដារ ហើយបើយើងនិយាយអស់តាមនោះទៅ សិស្សពុំអាចរៀនកើតឡើយ ព្រោះគ្នាមានវ័យនៅក្មេងផង ចំណេះនៅស្ដួចផង ហើយមានម៉ោងរៀនកំណត់ទៀតផង ។ ដូច្នេះ ចំពោះសេចក្ដីពិស្ដារនោះ សូមពឹងពាក់ទាំងស្រុងទៅលើលោកគ្រូ-អ្នកគ្រូ ពន្យល់បន្ថែមផង ។

ដើម្បីឲ្យងាយប្រើការ សៀវភៅនេះ យើងបានរៀបចំ

ក្នុងមេរៀននីមួយៗ ចែកជាបីផ្នែក គឺ៖

១-សេចក្ដីបរិយាយ.- សំរាប់បរិយាយឲ្យទូលាយន័យបន្តិច គ្រាន់នឹងគ្រូអានជាមុន ឲ្យយល់ច្បាស់ខ្លួនឯងសិន មុននឹងយកមេរៀននោះ ទៅពន្យល់សិស្ស ។

២-មេរៀនសង្ខេប.- សំរាប់គ្រូដកស្រង់យកទៅចម្លងដាក់ក្ដារខៀន ឲ្យសិស្សកត់ដាក់ក្នុងសៀវភៅ យកទៅទន្ទេញ ។ ដូច្នេះ យើងសរសេរកាត់ខ្លីៗ ល្មមតែយល់ ។

៣-ការចោទសួរឡើងវិញ.- សំរាប់ជាជំនួយស្មារតីចំពោះលោកគ្រូ-អ្នកគ្រូ ចោទសួរសិស្ស ក្រោយដែលបានស្ដាប់ពន្យល់ហើយ ឬ ទន្ទេញចាំរួចហើយ ។ ព្រោះថាជួនកាលសិស្សគ្រាន់តែចាំពាក្យមែន តែឥតយល់ន័យពាក្យ ឬន័យអត្ថបទនោះទេ គោងតែសួរល្បងមើល បើពិតជាយល់ច្បាស់ សិស្សក៏អាចឆ្លើយរួចយ៉ាងងាយដែរ ។

ចំពោះមេរៀននីមួយៗ គួរតែរៀនជាពីរលើក គឺលើក

ជំបូន៍គ្រាន់តែពន្យល់ឲ្យស្តាប់បាន រួចឲ្យចម្លងមេរៀនទុកក្នុង សៀវភៅ ។ លើកទី ២ សឹមហៅឲ្យសិស្សសូត្រឡើងវិញ ឬ ចោទសួរល្បងមើលឲ្យបានសព្វគ្រប់ ។ ក្រៅពីវិធីពន្យល់ ន័យតាមសៀវភៅនេះ សូមលោកគ្រូ-អ្នកគ្រូ រកសម្ភារៈខ្លះ ដែលទាក់ទងនឹងមេរៀនមកជួយផ្សំផង ដូចជាពេលរៀនពី អត្រានុកូលដ្ឋាន ត្រូវមានក្រដាសស្រង់បញ្ជីជាតិ, ពេលរៀន ពីភូមិស្រុក គួរមានរូបផែនទី ។ល។ ព្រោះការពន្យល់ សិស្សដោយមានរបស់បញ្ជាក់ឲ្យឃើញផងនោះ អាចធ្វើឲ្យ សិស្សឆាប់យល់ ហើយចាំបានយូរផង ។

ដូច្នេះ សូមលោកគ្រូ-អ្នកគ្រូមេត្តាទុកកូនសៀវភៅនេះ ជាជំនួយមួយ កុំមែនជាគ្រូបាធ្យាយធំដុំណាស់ណាឡើយ ។

PROGRAMME DE L'ENSEIGNEMENT PRIMAIRE

# INSTRUCTION CIVIQUE

(Enseignement donné exclusivement en Cambodgien)

## 1er TRIMESTRE :

(Septembre, Octobre, Novembre, Décembre)

*Déclaration d'état civil* :

— mariage

— naissance

— décès

— utilité de ces actes d'état civil.

*Le Phum* : Histoire, formation et Organisation.

— Le Méphum et son rôle.

*Le Khum* : Histoire, formation et Organisation.

— Le Mékhum et ses collaborateurs, Election du Mékhum,

— Devoirs du Mékhum et de ses collaborateurs,

— Mœurs et coutumes du villageois et évolution de la vie sociale et économique,

— Droits des habitants à l'instruction, au vote, à la sécurité et au bien-être.

— Devoirs des habitants : respecter et obéir aux autorités du Khum, respecter des biens publics du Khum, payer les impôts, participer aux travaux d'intérêt général menés par le Mékhum.

— Revision trimestrielle.

ត្រីមាសទី ១.-

ខែកញ្ញា - តុលា - វិច្ឆិកា - ធ្នូ

មេរៀនទី ១ : អំពីអត្រានុកូលដ្ឋាន

## ក- សេចក្តីបរិយាយ.-

ដែលហៅថាអត្រានុកូលដ្ឋាន គឺបញ្ជីសំរាប់កត់ជំរឿនមនុស្សដែលរស់នៅក្នុងប្រទេសឲ្យដឹងថា ឆ្នាំណាមានមនុស្សប៉ុន្មាននាក់ៗ នៅសង្កាត់នីមួយៗ ដែលរួមទៅជាមនុស្សបំណុះស្រុក និង បំណុះខែត្រ ៗ មិនតែប៉ុណ្ណោះ បញ្ជីនេះត្រូវកត់ត្រានូវចំនួនមនុស្សកើត, មនុស្សរៀបអាពាហ៍ពិពាហ៍ និង មនុស្សទទួលមរណភាព ដូច្នេះបើហៅឲ្យចំថាៈ អត្រានុកូលដ្ឋាន គឺជាកំណត់បញ្ជី កត់ចំនួនមនុស្សក្នុងស្រុកក្នុងប្រទេស ឲ្យដឹងថា ក្នុងមួយឆ្នាំ ៗ មានមនុស្សកើតប៉ុន្មាននាក់, រៀបអាពាហ៍-ពិពាហ៍ប៉ុន្មាននាក់ និង ស្លាប់ទៅវិញប៉ុន្មាននាក់ ហើយមនុស្ស

កើតជា មនុស្សរៀបការ និង អ្នកស្លាប់នោះឈ្មោះអ្វី? កូនទៅនរណា? ក៏គេដឹងបានដោយសារបញ្ជីនេះដែរ ។

អ្នកដែលមានសិទ្ធិកាន់បញ្ជីអត្រានុកូលដ្ឋាននេះ គឺជាមេសង្កាត់ ដែលទៅធ្វើការផ្ទាល់ជាមួយអ្នកស្រុកនោះឯង ។ បញ្ជីនេះ ត្រូវបំរុងជាពីរច្បាប់ គឺតម្កល់នៅសាលាស្រុកមួយ និងនៅសាលាដំបូងមួយ ។

## ១- សេចក្តីសង្ខេប .-

### អំពីអត្រានុកូលដ្ឋាន

ដែលហៅថាអត្រានុកូលដ្ឋាន គឺជាបញ្ជីសំរាប់កត់ចំនួនមនុស្សកើត រៀបការពាហ៍ពិពាហ៍ និងមនុស្សស្លាប់ ។ ដោយសារបញ្ជីអត្រានុកូលដ្ឋាន ទើបគេដឹងចំនួនមនុស្ស នៅក្នុងសង្កាត់ ក្នុងស្រុក និង ក្នុងខេត្តនិមួយៗ ។

អ្នកដែលមានអំណាចកាន់បញ្ជីអត្រានុកូល-

ដ្ឋាន គឺមេសង្កាត់ ដែលត្រូវចំឡងបញ្ជីនេះ ជាពីរច្បាប់ទុកនៅសាលាស្រុក១និងនៅសាលាដំបូង១ ។

## គ– ការចោទសួរឡើងវិញ .–

– អ្វីហៅជាអត្រានុកូលដ្ឋាន ?

– បញ្ជីអត្រានុកូលដ្ឋាន មានប្រយោជន៍ឲ្យដឹងពីអ្វី ?

– នរណាជាអ្នកកាន់អត្រានុកូលដ្ឋាន ?

– គេត្រូវចំឡងជាប៉ុន្មានច្បាប់ ? ទុកនៅឯណាខ្លះ ?

– ឈ្មោះអ្នក បានចុះនៅក្នុងអត្រានុកូលដ្ឋានឬទេ ?

– តើចុះនៅក្នុងសង្កាត់ណា ?

## មេរៀនទី ២ : លិខិតអត្រានុកូលដ្ឋាន

### ក- សេចក្តីបរិយាយ.-

*អត្រានុកូលដ្ឋានចែកចេញជាបីផ្នែកគឺ ៖*

*១ - កំណើត.- សំរាប់កត់នាម និង វង្សត្រកូលអ្នកដែលទើបនឹងកើត គឺថាបើមានកូនកើតភ្លាម ឪពុកឬញាតិកូននោះឬជនណាមួយ ដែលឃើញកូននោះកើត ត្រូវទៅប្តឹងមេសង្កាត់ឲ្យចុះក្នុងបញ្ជី ក្នុងរយៈពេល ១៥ ថ្ងៃ ។*

*២ - អាពាហ៍ពិពាហ៍.- មុននឹងរៀបការកូន ឪពុកម្តាយខាងស្រីត្រូវទៅប្តឹងមេសង្កាត់ឲ្យប្រកាសផ្សាយដំណឹង ។ លុះការរួចហើយឪពុកម្តាយទាំងសងខាង ត្រូវនាំកូនប្រុស-ស្រី និង កសិណពីរនាក់ទៅប្តឹងមេសង្កាត់ ឲ្យចុះក្នុងបញ្ជីថា ឈ្មោះនេះជាកូនឈ្មោះនេះ បានរៀបការគ្នាត្រឹមត្រូវមានកសិណឈ្មោះនេះ ជាអ្នកដឹងឮ ។*

៣-មរណភាព. បើមានជនណាស្លាប់ក្រុមញាតិ សន្តាននៃសពនោះ ត្រូវទៅប្តឹងមេសង្កាត់ឲ្យចុះបញ្ជីថា ជននោះស្លាប់នៅពេលណា ថ្ងៃខែឆ្នាំណា ក្នុងកំណត់ពេល ៣ ថ្ងៃក្រោយមកយ៉ាងយូរ ។

ចំពោះលិខិតទាំងបីនេះបើហួសពីថ្ងៃកំណត់ ត្រូវប្តឹងទៅតុលាការសុំឲ្យចេញសាលក្រមសម្រេចសេចក្តី ទើបចុះបាន ។ ចុះបញ្ជីហើយ, អ្នកប្តឹងត្រូវសុំចម្លងសេចក្តីដកស្រង់អំពីបញ្ជីដើម យកមកទុកប្រើការផ្សេងៗ ដូចជាសំបុត្រកំណើត សំរាប់ប្រើក្នុងការសុំចូលរៀន សុំប្រឡង សុំសំបុត្របញ្ជាក់អ្វីដទៃទៀតជាដើម ។ សំបុត្រអាពាហ៍ពិពាហ៍ និង មរណភាពក៏មានប្រយោជន៍ក្នុងការសំគាល់វង្សត្រកូល ឬ ការបែកមត៌កជាដើម ។ សេចក្តីដកស្រង់នេះ ត្រូវមានហត្ថលេខាមេសង្កាត់ជាមន្ត្រីកាន់បញ្ជីអត្រានុកូលដ្ឋាន និង មានបញ្ជាក់ពីអភិបាលស្រុក និង អភិបាលខេត្តផង ។

## ១- សេចក្តីសង្ខេប .–

អត្រានុកូលដ្ឋានបែកចេញជាបីយ៉ាងគឺ ៖

កំណើត អាពាហ៍ពិពាហ៍ និង មរណភាព ។

កំណើតត្រូវចុះក្នុងរយៈ ១៥ ថ្ងៃ, មរណភាពកំណត់ ៣ ថ្ងៃ បើហួសពីកំណត់នេះ ត្រូវសុំសាលក្រម ពីសាលាដំបូង ។ ចុះហើយគេត្រូវសុំចំឡងយក សេចក្តីស្រង់ពីច្បាប់ដើម សំរាប់ប្រើការផ្សេងៗ ដូចជាសុំចូលរៀន សំគាល់វង្សត្រកូល ឬ ការបែកមត៌កជាដើម ។

សេចក្តីចំឡងនេះ ត្រូវមានចុះហត្ថលេខាមេ-សង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋាន និងបញ្ជាក់ពី អភិបាលស្រុក និង ខេត្ត ផង ។

## គ- ការចោទសួរឡើងវិញ .–

– អត្រានុកូលដ្ឋាន បែកចេញជាប៉ុន្មានយ៉ាង ?

– គឺអ្វីខ្លះ ?

– ប្ដឹងចុះហើយ គេត្រូវធ្វើដូចម្ដេច ?

– លិខិតបំឡង មានប្រយោជន៍អ្វីខ្លះ ?

– បំឡងហើយ ត្រូវធ្វើដូចម្ដេចទើបប្រើការបាន ?

– គេត្រូវប្ដឹងចុះក្នុងរយៈប៉ុន្មានថ្ងៃ ?

– បើហួសកំណត់នេះ គេត្រូវធ្វើដូចម្ដេច ?

មេរៀនទី ៣ :

# អំពីភូមិ

## ក – សេចក្ដីបរិយាយ .–

ភូមិនីមួយ ៗ មានឈ្មោះហៅជាគ្រឿងចំណាំ ៗ ឈ្មោះភូមិ គេច្រើនប្រឌិតយកតាមលំនាំទឹកដី ដូចជាមានជាទួលជាចិន ឬមានដើមឈើអ្វីមួយជាគ្រឿងសំគាល់ ឬមានឈ្មោះវត្ត ឬវត្ថុសក្ការៈផ្សេងៗ ទៀត ដែលមាននៅក្នុងទីនោះ(១)ដូចជាហៅថាៈ ទួលស្វែង, ចុងចិន, ត្រៃផ្ដៅ, វត្តចាស់, ប្រាសាទបាក់ ដូច្នេះជាដើម ។ ម្ល៉ោះហើយ គេសង្កេតឃើញមានភូមិឈ្មោះដូចគ្នាក៏មាន ព្រោះតែភូមិនោះ មានលក្ខណៈដូចគ្នា ។

ដែលសន្មតថាជាភូមិមួយបាន លុះណាតែមានផ្ទះអ្នកស្រុកសង់នៅប្រជុំគ្នាប្រមូលផ្តុំជិតៗ គ្នា អាចរួបរួមគ្នាជាចំនួន

---

១ – ត្រង់នេះ សូមលោកគ្រូ-អ្នកគ្រូ យកឈ្មោះភូមិពីរ-បី ដែលនៅជិត ៗ សាលា មកបញ្ជាក់ជាឧទាហរណ៍ផង ។

ផ្ទះមួយក្រុម ។ បើចំនួនផ្ទះតិចពេក ពុំមានលក្ខណៈពេញលេញជាភូមិទេ ។

ភូមិដែលមានលក្ខណៈគ្រប់គ្រាន់នេះ ត្រូវមានមន្ត្រីរាជការជាសមាជិកគណៈកម្មការសង្កាត់ ធ្វើជាតំណាងរាជការនៅប្រចាំទីនេះ មានឈ្មោះថា "មេភូមិ" ។ បើអ្នកស្រុកក្នុងភូមិមានទុក្ខធុរៈអ្វី ត្រូវប្រស្រ័យនឹងរាជការ ឬមានសំបុត្រស្នាមអ្វីពីរាជការ ត្រូវប្រស្រ័យនឹងរាស្ត្រ, មេភូមិនេះហើយជាអ្នកនាំការនេះ ឬមួយបើមានហេតុទាស់ទែង ឬបាត់ការកសាងក្នុងភូមិ ក៏ជាមុខងាររបស់មេភូមិនេះដែរ ជាអ្នកសម្រុះសម្រួល ឬ ជួយណែនាំធ្វើឲ្យកើតឡើង ។

## ១– សេចក្ដីសង្ខេប ·–

ភូមិនីមួយៗ គេសន្មតបាន ដោយសារមានមនុស្សរស់នៅសង់ជាផ្ទះនៅផ្ដុំគ្នា ។ គេដាក់ឈ្មោះភូមិទៅតាមលក្ខណៈទីកន្លែង ឬ តាមរឿង

រ៉ាវចាស់ៗ ដែលធ្លាប់ឮតៗគ្នាមក ។

នៅក្នុងភូមិនីមួយៗ ត្រូវមានជ្រើសតាំងម្នាក់ ងារជា "មេភូមិ" នៅជាតំណាងរាជការប្រចាំភូមិនោះៗ មេភូមិ មានមុខងារជាអ្នកប្រស្រ័យការ ងារពីរាជការទៅរាស្ត្រ និង ពីរាស្ត្រទៅរាជការវិញ ព្រមទាំងមើលការខុស-ត្រូវក្នុងភូមិទាំងអស់ ឲ្យត្រូវតាមលក្ខណៈច្បាប់ ។

## គ- ការចោទសួរឡើងវិញ .-

- ភូមិនីមួយៗ កើតឡើងដោយសារអ្វី ?
- គេដាក់ឈ្មោះភូមិដោយសន្មតតាមអ្វី ?
- មានអ្នកណាជាអ្នកកាន់ការរាជការប្រចាំភូមិ ?
- មេភូមិមានមុខងារធ្វើអ្វីខ្លះ ?
- សព្វថ្ងៃនេះអ្នក នៅក្នុងភូមិអ្វី ?

– ហេតុអ្វីក៏គេដាក់ឈ្មោះភូមិអ្នកដូចនេះ ?

– ភូមិអ្នកនៅក្នុងសង្កាត់ណា ?

– ភូមិអ្នក មានផ្ទះប្រហែលប៉ុន្មាន ?

## មេរៀនទី ៤ : អំពីសង្កាត់

### ក_ សេចក្ដីបរិយាយ .–

“សង្កាត់” ជាពាក្យថ្មីសំរាប់ប្រើជំនួសពាក្យ “ឃុំ” ។ សង្កាត់នីមួយៗកើតឡើងដោយការប្រជុំភូមិជាច្រើនរួមបញ្ចូលគ្នា ។ ការរៀបចំនៅក្នុងសង្កាត់ ត្រូវមានមន្ត្រីរាជការ ឆ្នោរជា“ចៅសង្កាត់”(១) ធ្វើជាមេ ព្រមទាំងមានគណៈកម្មការមួយជាជំនួយ ធ្វើការរួមផង ។ គណៈកម្មការ និងចៅសង្កាត់នីមួយ ៗ ត្រូវកស្ដ្រោះបោះឆ្នោតរើសក្នុងរយៈពេល ៤ ឆ្នាំម្ដង ។ សមាជិកនៃគណៈកម្មការនេះ អាចធ្វើជាសហការីផ្ទាល់របស់ចៅសង្កាត់ ដូចជាជំទប់ ២ ឬ ៣ នាក់ ប្រចាំសង្កាត់នីមួយៗ និងធ្វើជាក្រុម-មេភូមិ តាមដែលគណៈកម្មការចាត់ចែងចែកមុខការឲ្យផ្សេងៗគ្នា ។

---

១– ពាក្យនេះពីដើមមកហៅថា “មេឃុំ” ឯគណៈកម្មការ ហៅ ក្រុមការឃុំ ។

ឈ្មោះសង្កាត់ទាំងនេះ ច្រើនយកតាមនាមភូមិណាដែលធំជាងគេ ឬនាមភូមិណាដែលនៅត្រង់ទីតាំងជាមន្ទីរចាត់ការប្រចាំសង្កាត់នោះ ។ បើនៅក្នុងក្រុងភ្នំពេញ នាមសង្កាត់ដាក់ជាលេខរៀង តាមភូមិភាគហូរហែគ្នា តាមលំដាប់កំណើតកើតមុនកើតក្រោយ ។

ចៅសង្កាត់មានមុខងារមើលការខុស-ត្រូវ ក្នុងសង្កាត់របស់ខ្លួន និងប្រស្រ័យការរាជការជាមួយបណ្ដារាស្ត្រសព្វសារពើ ព្រមទាំងទទួលប្រាក់ពន្ធដារដែលរាស្ត្រត្រូវបង់ផង ។ មិនតែប៉ុណ្ណោះ ចៅសង្កាត់ជាតំណាងរាជការគ្រប់ក្រសួងមើលការថែទាំសម្បត្តិសាធារណៈ ដូចជាផ្លូវថ្នល់ ស្ពានសាលារៀន ។ល។ ព្រមទាំងត្រូវតែណែនាំអ្នកស្រុកឲ្យជួយកសាង និង ជួយថែរក្សារបស់ទាំងនោះផង ។ ក្រៅពីនេះត្រូវមើលថែទាំសុខទុក្ខរាស្ត្រ និងជួយឲ្យមានការចំរើនដល់អ្នកស្រុក ។

## ខ- សេចក្តីសង្ខេប .-

សង្កាត់កើតឡើងដោយការប្រជុំភូមិជាច្រើន ដែលនៅជិតៗគ្នា ។ សង្កាត់នីមួយៗត្រូវមានមេសង្កាត់ ជាអ្នកកាន់កាប់ការ ដោយមានជំទប់, ក្រម , ស្មៀន និង មេភូមិជាគណៈកម្មការសង្កាត់ ជួយរួមធ្វើការងារ ។

មេសង្កាត់ និង គណៈកម្មការនេះ ត្រូវរាស្ត្របោះឆ្នោតរើសក្នុងរយៈ ៨ ឆ្នាំម្តង ។

មុខងារនៃមេសង្កាត់ គឺធ្វើជាតំណាងរាជការជំគ្រប់មុខក្រសួង និងមានភារៈជាអ្នកជួយកសាងសង្កាត់របស់ខ្លួនឲ្យបានរីកចំរើន ។

## គ- ការចោទសួរឡើងវិញ .-

- ដូចម្តេចដែលហៅថាសង្កាត់ ?
- សង្កាត់នីមួយៗ មាននរណាជាអ្នកកាន់កាប់ ?

— មាននរណាខ្លះជាជំនួយ ?

— ចៅសង្កាត់និងគណៈកម្មការតាំងឡើងដោយវិធីណា?

— ចៅសង្កាត់មានមុខងារធ្វើអ្វីខ្លះ ?

— សព្វថ្ងៃខ្លួនអ្នកនៅក្នុងសង្កាត់ណា ?

— ឈ្មោះសង្កាត់នេះ យកតាមអ្វី ?

## មេរៀនទី ៥ : អំពីជីវភាពបញ្ញាជន

### ក- សេចក្ដីបរិយាយ .-

ជីវភាពរបស់អ្នកស្រុកខ្មែរយើង ច្រើនជាប់ទៅក្នុងទំនៀមទំលាប់ ដែលមានមកតាំងពីដូនតាតៗមក ដូចជាក្នុងពិធីបុណ្យផ្សេងៗ, ពិធីអាពាហ៍ពិពាហ៍ និង បុណ្យសព ជាដើម ។ មិនតែប៉ុណ្ណោះ ខ្មែរស្ទើរតែទាំងអស់ សុទ្ធតែជាអ្នកគោរពពុទ្ធសាសនា កាន់សីលព្រះពុទ្ធធ្វើជាជំបូន្មានអប់រំខ្លួន ឲ្យចេះស្លូតបូត, ស្មោះត្រង់, ហើយស្រឡាញ់រាក់ទាក់ទៅគេក្បែរ ៗ កាលសម័យដើម មានជំនឿត្រៃផ្សេង ដូចជាជឿខ្មោចបិសាចអារក្សអ្នកតា និង មន្តអាគមច្រើនណាស់ ៗ ប៉ុន្តែសព្វថ្ងៃគេបានបែរមកជឿវិទ្យាសាស្ត្រ និយមពេទ្យ កែរោគដោយឧសថផ្សេងៗ និងចេះអនាម័យតាមសម័យថ្មីផង ។ ការរៀនសូត្រជំនាន់ដើម គឺគេរៀននៅតែតាមវត្តអារាម ឯស្រីៗពុំ

បេះសត្វរេទ លុះដល់សព្វថ្ងៃ គេបានរៀនសូត្រទាំងប្រុស-ស្រី នៅតាមសាលានានា នៅក្នុងស្រុករបស់ខ្លួន ។

របរសំខាន់របស់អ្នកស្រុកខ្មែរ គឺកសិកម្ម ។ អ្នកនៅតាមមាត់ទន្លេ គេធ្វើចំការ ឯក្រៅពីនេះធ្វើស្រែ យកផលជាស្រូវ, ពោត, សណ្តែក, ថ្នាំជក់, កប្បាស, ល្ង ។ល។ មានអ្នកប្រកបរបរជំនួញគាតតិចណាស់ គឺមានតែត្រង់ទីណាជាស្រុកធំប្រជុំជន មានផ្សារផ្សាប៉ុណ្ណោះ ។ ឧស្សាហកម្មកើតកើនឡើងឥឡូវមាននៅក្នុងស្រុកខ្លះ បាត់ជាសម្បត្តិសំខាន់ដែរៗ

ផលដំណាំរបស់អ្នកស្រុកនេះហើយ ដែលជាសម្បត្តិរបស់សង្កាត់នីមួយៗ គឺថាបើសង្កាត់ធ្វើដំណាំបានផលច្រើន ប្រាក់ពន្ធក៏បានច្រើន អ្នកស្រុកក៏ធូរធារ ។

១ - សេចក្តីសង្ខេប :-

> ដោយសាររំនៀមខ្មែរជាអ្នកកាន់ពុទ្ធសាសនាគ្រប់គ្នា, ម្ល៉ោះហើយចិត្តគំនិតខ្មែរ ក៏មាននិស្ស័យ

ស្លូតបូតនិងរួសរាយរាក់ទាក់ជានិច្ច ។ ពីដើមខាងជំនឿព្រាយផ្សងច្រើន ប៉ុន្តែសព្វថ្ងៃ គេបានងាកបែរមកជឿតាមវិទ្យាសាស្ត្រវិញ គឺចេះអនាម័យនិយមពេទ្យហ្មនិងឱសថផ្សំតាមសម័យថ្មី ។ ឯការរៀនសូត្រ ក៏កំពុងតែជឿនលឿនយ៉ាងខ្លាំង ។

របរសំខាន់របស់អ្នកស្រុកខ្មែរ គឺធ្វើស្រែនិងធ្វើចំការ ។ សព្វថ្ងៃកំពុងកើនខាងឧស្សាហកម្ម ឯអ្នកជំនួញមានចំនួនតិចនៅឡើយ ។ ផលរបរទាំងនេះ ជាសម្បត្តិរបស់សង្កាត់នីមួយៗ ។

## គ- ការចោទសួរឡើងវិញ .–

- ហេតុអ្វីបានជាខ្មែរមាននិស្ស័យស្លូតបូតនិងរាក់ទាក់ ?
- ពីដើមអ្នកស្រុកចូលចិត្តជំនឿអ្វី ? ចុះសព្វថ្ងៃ ?
- ការរៀនសូត្របានលូតលាស់ឬទេ? ឲ្យឧទាហរណ៍!
- អ្នកស្រុកខ្មែរមានរបរអ្វីជាសំខាន់ ?

— កាលណាមានផលឈើច្រើន តើគេបាត់សង្កត់ទោះមានភាពដូចម្ដេច ?

— អ្នកភូមិអ្នកស្រុកយកឈើធ្វើអ្វីខ្លះ ?

— អ្នកដែលឃើញគេធ្វើពិធីផ្សេងៗ ឬទេ ?

## មេរៀនទី ៦ : សិទ្ធិរបស់អ្នកស្រុក

### ក- សេចក្ដីបរិយាយ .-

បណ្ដាជនដែលរស់នៅក្នុងភូមិ ក្នុងសង្កាត់ទាំងអស់ហៅ ថា "ពលរដ្ឋ" ។ អ្នកទាំងនេះ ត្រូវមានសិទ្ធិរបស់ខ្លួនតាមច្បាប់ បានចែងទុក, គឺជាអំណាចដែលត្រូវតែបានទទួលជាចាំបាច់គឺ៖

១- សិទ្ធិក្នុងការចេះដឹង.- បានសេចក្ដីថា ពលរដ្ឋម្នាក់ៗ ត្រូវតែបានទទួលការចេះដឹងដូចៗគ្នា គឺត្រូវ មានសាលារៀនតាំងពីតូចមក គឺសាលាសាធារណៈនៅក្នុង ភូមិឬក្នុងសង្កាត់របស់ខ្លួន ។ កូនជនណាក៏ដោយ ឲ្យតែ អាយុ ៧ ឆ្នាំបរិបូណ៌ហើយ ត្រូវតែបានរៀនដូចៗគ្នា ហើយ អាចធ្វើជាមន្ត្រី ឬ ជ្រើសរើសរបរអ្វីមួយតាមខ្លួនស្ម័គ្រ ។

២- សិទ្ធិក្នុងការបោះឆ្នោត.- ការបោះឆ្នោត គឺជាការសម្ដែងមតិយល់ឃើញរបស់ជនមួយៗ ក្នុងការទុក

ចិត្ត ឬជ្រើសរើសតាំងនរណាមួយជាតំណាងខ្លួន ៗ ផងទាំងប្រុស-ស្រី ដែលមានអាយុ ២០ ឆ្នាំបរិបូណ៌ហើយ ត្រូវតែបានបោះឆ្នោត, បើអាយុ ២៥ ឆ្នាំហើយ អាចឈរឈ្មោះឲ្យគេជ្រើសខ្លួនបាន ។

៣ - សិទ្ធិក្នុងសន្តិសុខ .- ច្បាប់ និង អ្នកកាន់អំណាចច្បាប់ គឺជាអ្នកធានាអះអាងឲ្យបានសេចក្តីសុខស្ងប់ក្នុងភូមិស្រុក សម្រាប់ឲ្យបណ្តាជនរស់នៅសុខក្សេមក្សាន្ត ។ ដូច្នេះ ពលរដ្ឋទាំងអស់ ត្រូវតែបានច្បាប់ការពារឲ្យបានសុខសាន្តត្រាណដូច ៗ គ្នា ។

៤ - សិទ្ធិក្នុងសុខុមាលភាព .- ពលរដ្ឋទាំងអស់ ត្រូវតែបានទទួលការថែទាំជម្ងឺ រក្សាការពារនឹងរោគផ្សេង ៗ កុំឲ្យឈឺធ្ងន់បាន ។ ដូច្នេះ មន្ទីរពេទ្យមានមុខងារជាអ្នកជួយរក្សាសេចក្តីសុខ រំងាប់ជម្ងឺកុំឲ្យកើតមានឡើងបាន ។

## ១- សេចក្ដីសង្ខេប .–

អ្នកស្រុកដែលរស់នៅក្នុងភូមិទាំងអស់ គេហៅថាពលរដ្ឋ ។ ពលរដ្ឋទាំងអស់ ត្រូវបានសិទ្ធិ គឺអំណាចដែលត្រូវមានតាមច្បាប់ចែងទុកឲ្យ គឺ៖

សិទ្ធិក្នុងការចេះដឹង ដែលត្រូវតែបានទទួលការសិក្សា តាំងពីខ្លួនមានអាយុល្មមចូលរៀនបាន។ សិទ្ធិក្នុងការបោះឆ្នោតបញ្ចេញមតិ ឲ្យតែខ្លួនមានអាយុ២០ឆ្នាំ និង មានអាយុ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេជ្រើសតាំងខ្លួនបាន។ សិទ្ធិក្នុងការរក្សាសន្តិសុខ និង ក្នុងការព្យាបាលរោគកុំឲ្យមានកើតរោគផ្សេងៗ។

## គ- ការហោទសួរឡើងវិញ .–

– អ្នកណាខ្លះដែលហៅថាពលរដ្ឋ ?

– ដូចម្ដេចហៅថាសិទ្ធិ ? ចូរឲ្យឧទាហរណ៍ !

– ពលរដ្ឋត្រូវបានទទួលសិទ្ធិតាមច្បាប់ ដូចម្ដេចខ្លះ ?

– អាយុប៉ុន្មានត្រូវចូលរៀន ? ប៉ុន្មានត្រូវបោះឆ្នោត ?

– ហេតុអ្វីបានជាត្រូវឲ្យមានសុខស្ងប់ក្នុងស្រុក ?

– បើមានជម្ងឺកើតឡើង អ្នកស្រុកត្រូវពឹងនរណា ?

– ខ្លួនអ្នក បានប្រើសិទ្ធិអ្វីខ្លះហើយនៅ ?

– ក្នុងការបានមករៀនសូត្រនេះ ចាត់ជាប្រើសិទ្ធិឬទេ ?

## មេរៀនទី ៧ : ករណីយកិច្ច នៃ អ្នកស្រុក

### ក- សេចក្តីបរិយាយ .-

ពលរដ្ឋ ឬ អ្នកស្រុក នៅក្នុងសង្កាត់នីមួយៗ ត្រូវមានករណីយកិច្ច ជួយកសាងជាតិ និងគោរពច្បាប់ ដូចតទៅនេះ ៖

– ត្រូវតែគោរពតាមច្បាប់រាជការប្រចាំសង្កាត់ដែលខ្លួននៅ គឺមិនត្រូវធ្វើអ្វីឲ្យខុសពីច្បាប់ឡើយ ។ ការងារណាដែលច្បាប់មិនតម្រូវឲ្យធ្វើទេ ពលរដ្ឋមិនត្រូវធ្វើឡើយ ។

– សម្បត្តិសាធារណៈ ដែលមាននៅក្នុងសង្កាត់របស់ខ្លួន ដូចជាផ្លូវថ្នល់, ស្ពាន, សាលារៀន, ឬមន្ទីររាជការផ្សេងៗ ត្រូវតែនាំគ្នាជួយថែទាំកុំឲ្យខូចខាត ហើយនិងត្រូវជួយឧបត្ថម្ភកសាងថ្មី ឬ ជួសជុលឲ្យបានល្អត្រឹមត្រូវផង ។

– ត្រូវបង់ពន្ធដារតាមកំណត់ច្បាប់ដែលតម្រូវឲ្យបង់ ដូចជា ពន្ធដី, ពន្ធអាករលើមុខជំនួញជាដើម ព្រោះប្រាក់ពន្ធ

នេះហើយ ដែលរាជការគាបយកទៅកសាងជាតិ ដូចជា បង្កើតសាលា, ឲ្យរៀនសូត្រ, ក្រាលផ្លូវថ្នល់ ។ល។

— ត្រូវបេះរួបរួមគ្នារក្សាសេចក្តីសុខរៀបរយក្នុងសង្កាត់របស់ខ្លួន ហើយត្រូវមានចិត្តស្មោះត្រង់ទិសរាជការជានិច្ចផង ។

– ត្រូវចូលរួមក្នុងការងារ កសាងសាធារណប្រយោជន៍ ដូចជាលើកថ្នល់, សង់ស្ពាន, លើកទំនប់ទឹក, កសាងសាលា ឬមន្ទីរពេទ្យជាដើម ។ កាលណា បើមេសង្កាត់ផ្តើមគំនិតក្នុងកិច្ចការទាំងនេះ ពលរដ្ឋត្រូវតែមមាញជួយរួមកម្លាំងឲ្យបានសម្រេចឡើង ។

## ១- សេចក្តីសង្ខេប .–

ពលរដ្ឋនៅក្នុងសង្កាត់ ត្រូវមានករណីយកិច្ចដូចតទៅ៖

– ត្រូវបេះគោរពច្បាប់រាជការ ដែលមានមេសង្កាត់ជាអ្នកកាន់កាប់ និង ត្រូវឲ្យយោបល់ដោយការបោះឆ្នោត ។

- ត្រូវបេះជួយថែទាំសម្បត្តិសាធារណៈ មាន ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម ។

- ត្រូវបង់ពន្ធដារឲ្យត្រឹមត្រូវតាមច្បាប់តម្រូវ ។

- ត្រូវរួមកំឡាំងគ្នា រក្សាសន្តិសុខក្នុងសង្កាត់ និងបេះជួយបំពេញការងារកសាងជាតិ ដែលនៅសង្កាត់បានចាត់ចែងឡើង ។

## គ- ការចោទសួរឡើងវិញ .-

- តើពលរដ្ឋនៅក្នុងសង្កាត់ មានករណីយកិច្ចដូចម្តេចខ្លះ?
- ហេតុអ្វី បានជាត្រូវថែទាំសម្បត្តិសាធារណៈ ?
- ប្រាក់ពន្ធដារ រាជការយកទៅធ្វើអ្វីខ្លះ ?
- ក្នុងសង្កាត់ដែលអ្នកនៅ មានសម្បត្តិសាធារណៈម្តេច?
- តើមានអ្វីខ្លះ ? ចូររាប់ឈ្មោះ !
- អ្នកដែលឃើញ ពលរដ្ឋជួយធ្វើការកសាងជាតិអ្វីខ្លះ?

## មេរៀនទី ៨ : រៀនសារឡើងវិញ

### ក- សេចក្តីបរិយាយ .-

ភូមិគឺជាទីប្រជុំដែលមានមនុស្សរស់នៅជុំគ្នាច្រើនផ្ទះ ។ ភូមិប្រជុំគ្នាកើតបានជាសង្កាត់, សង្កាត់រួមគ្នាជួនតិចជួនច្រើន កើតបានជាស្រុក, ហើយស្រុកប្រមូលផ្តុំគ្នាទៅទៀត ទើបកើតបានជាខេត្ត ។ អ្នកគ្រប់គ្រងប្រចាំភូមិ ហៅថាមេភូមិ ដែលត្រូវនៅក្រោមអំណាចមេសង្កាត់ ឬ ចៅសង្កាត់ ។ អភិបាលស្រុកជាអ្នកកាន់ការក្នុងស្រុកតំណាងរាជការធំ ដោយមានសហការីជាមន្ត្រីរាជការនៃក្រសួងផ្សេងៗ នៅរួមធ្វើការជាមួយផង ។ អ្នកគ្រប់គ្រងការរាជការប្រចាំខេត្ត ហៅថាអភិបាលខេត្ត ។ ក្រុមរាជការផ្សេងៗទៀត គ្រប់តំណែងប្រចាំខេត្ត ត្រូវនៅក្រោមអំណាចអភិបាលខេត្ត ។

បណ្តាជននៅក្នុងភូមិ, សង្កាត់ និង ស្រុកទាំងនេះ ត្រូវ

បានទទួលសិទ្ធិរបស់ខ្លួនក្នុងការរៀនសូត្រឲ្យចេះដឹង ក្នុងការរក្សាសុខភាព និងសេចក្ដីសុខសាន្តត្រាណអំពីរាជការ ។ តែអ្នកទាំងនេះ ត្រូវមានករណីយកិច្ចជួយរាជការវិញ ដោយការបង់ពន្ធដារបញ្ចូលថវិកាជាតិ ជួយរក្សាថែទាំទ្រព្យសាធារណៈ មានផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យជាដើម ។ មិនតែប៉ុណ្ណោះ ត្រូវតែរួបរួមកម្លាំងជួយកសាងរបស់ទាំងនេះផង ។ ករណីយកិច្ចខាងនយោបាយមួយទៀត ត្រូវបោះឆ្នោតបញ្ចេញមតិរបស់ខ្លួន នៅពេលដែលរាជការត្រូវសាកសួរពីរឿងអ្វីមួយ ឬជ្រើសរើសតំណាងទៅធ្វើការនៅរដ្ឋសភា ។ ក្រៅពីនេះ ត្រូវតែគោរពច្បាប់ផែនដី ដែលចេញជាបញ្ញត្តិសម្រាប់ធ្វើឲ្យមានការរៀបរយក្នុងស្រុកភូមិ ។

## ១- សេចក្ដីសង្ខេប .–

ភូមិជាច្រើនរួមគ្នាកើតជាសង្កាត់ ។ សង្កាត់ច្រើនគ្នាកើតបានជាស្រុក ។ អ្នកកាន់កាប់ការ

ប្រចាំភូមិហៅថាមេភូមិ ដែលនៅក្រោមអំណាច មេសង្កាត់ ហើយមេសង្កាត់នេះ ត្រូវស្ដាប់បង្គាប់ អភិបាលស្រុក ។

បណ្ដាជនក្នុងភូមិ-ស្រុកនីមួយ ៗ ត្រូវមានសិទ្ធិក្នុងការបញ្ចេញមតិជាយោបល់របស់ខ្លួន ក្នុងការបោះឆ្នោត និងត្រូវបានទទួលការបេះដូង ការរក្សាសន្តិសុខ និងសុខុមាលភាពគ្រប់យ៉ាង ។ ប៉ុន្តែត្រូវមានករណីយកិច្ច បង់ពន្ធដារព្រមទាំងជួយថែរក្សានិងកសាងសម្បត្តិសាធារណៈផង ។

# គ- ការហាត់សួរឡើងវិញ.-

- ចូរពន្យល់ដូចម្ដេចហៅថា ភូមិ-សង្កាត់-ស្រុក ។
- អ្នកកាន់កាប់ការពារការប្រចាំទីតាំងនោះមានឈ្មោះអ្វីខ្លះ?
- បណ្ដាជនក្នុងភូមិ-ស្រុក មានសិទ្ធិដូចម្ដេចខ្លះ ?

- ហើយមានករណីយកិច្ច ត្រូវធ្វើអ្វីខ្លះ?

- ដូចម្ដេចហៅថា សម្បត្តិសាធារណៈ?

- អ្នកធ្លាប់ឃើញ សាលាសង្កាត់ សាលាស្រុកឬទេ?

# PROGRAMME

## 2ème TRIMESTRE

(Janvier, Février, Mars)

*Le Srok* : Histoire, formation et Organisation.

— les autres Khums dans le Srok,

— Aphibal-Srok et ses collaborateurs,

— leurs rôles : perception des impôts, développement social et économique du Srok,

— Schéma de l'organisation administrative du Srok,

— les divers services dans le Srok, leur fonctionnement, leur utilité,

— Droits des habitants à l'instruction, à la sécurité et au bien-être.

— Obéir aux autorités du Srok.

— Participer aux travaux d'intérêts général organisés par l'Aphibal-Srok,

— Revision trimestrielle.

# ត្រីមាសទី ២ .–

ខែមករា - កុម្ភៈ - មីនា

មេរៀនទី ៩ : **អំពីស្រុក**

## ក- សេចក្ដីបរិយាយ.–

*ដែលហៅថាស្រុក គឺជាទីប្រជុំសង្កាត់ច្រើនរួមគ្នា ។ ចំនួននេះពុំមានកំណត់ទេ ជួនច្រើនជួនតិចទៅតាមទំហំស្រុក ធំ ឬ ស្រុកតូច[១] ។ នាមស្រុកនីមួយៗ គេច្រើនយកតាមឈ្មោះ សង្កាត់ណាមួយដែលធំ ឬ សំខាន់ជាងគេក្នុងស្រុកនោះ ឬ មួយគេដាក់តាមឈ្មោះសង្កាត់ដែលធ្វើជាទីប្រជុំជននៃស្រុក គឺ កន្លែងតាំងទីមន្ទីរចាត់ការរាជការប្រចាំស្រុក ហៅថា " សាលា*

---

១ – ត្រង់នេះ សូមលោកគ្រូ-អ្នកគ្រូ យកឈ្មោះឃុំទាំងប៉ុន្មានដែលមាន នៅក្នុងស្រុករបស់ខ្លួនមករាប់ឲ្យសិស្សស្គាល់ផង ។

ស្រុក" ។

មន្ត្រីក្នុងក្របខណ្ឌរដ្ឋបាលម្នាក់ ជាមន្ត្រីជាន់មធ្យម ឬជាន់ខ្ពស់ ជាអ្នកកាន់ការប្រចាំស្រុកនីមួយៗ តំណាងរាជរដ្ឋាភិបាល ហៅថា "អភិបាលស្រុក" ។ អភិបាលស្រុក ត្រូវមានសហការីដូចតទៅជួយធ្វើការផងគឺ បាល័ដ្ឋស្រុក, លេខាធិការសាលាស្រុក និងស្មៀនជំនួយជាច្រើននាក់ទៀត ។ ពេលណា អភិបាលស្រុកពុំនៅ បាល័ដ្ឋស្រុកត្រូវធ្វើការជំនួសពេញលក្ខណៈច្បាប់ ។

ក្រៅពីសហការីផ្ទាល់នៅធ្វើការជាមួយ មានចៅសង្កាត់គ្រប់សង្កាត់ដែលនៅក្នុងអំណាចស្រុកនោះ ធ្វើជាតំណាងលោក នៅប្រចាំសង្កាត់រៀងខ្លួនផង ។

## ១- សេចក្តីសង្ខេប.-

សង្កាត់ជាច្រើនរួមបញ្ចូលគ្នាកើតបានជាស្រុក ។

ចំនួនសង្កាត់នៅក្នុងស្រុកនិមួយៗ មិនកំណត់ទេ ស្រេចតែមានទីតាំងនៅជិតខាងគ្នា ល្មមធ្វើដំណើរទាក់ទងបានស្រួល ។ ឈ្មោះស្រុក គឺយកតាមឈ្មោះសង្កាត់ឬទីប្រជុំជនណាដែលសំខាន់ជាងគេ ។

អ្នករាជការកាន់កាប់ការនៅក្នុងស្រុក ហៅថា អភិបាលស្រុក ដ៏មានបាល័ដ្ឋ និងលេខាធិការធ្វើការជាជំនួយផង ។ ទីកន្លែងធ្វើការរបស់អភិបាលស្រុក ហៅថា " សាលាស្រុក " ។

## គ- ការចោទសួរឡើងវិញ.-

- ដូចម្តេចហៅថាស្រុក ? ចំនួនសង្កាត់នៅក្នុងស្រុក មានកំណត់ឬទេ ?
- គេដាក់ឈ្មោះស្រុកយកតាមអ្វី ?
- អ្នករាជការកាន់កាប់ការក្នុងស្រុកហៅថាអ្វី ?

- អភិបាលស្រុកមាននរណាខ្លះជាសហការី ?
- បើអភិបាលស្រុកពុំនៅ នរណាជំនួសបាន ?
- អ្នកនៅក្នុងស្រុកណាសព្វថ្ងៃ ?

## មេរៀនទី ១០ : មុខងាររអភិបាលស្រុក

### ក– សេចក្ដីបរិយាយ .–

អភិបាលស្រុក ត្រូវមានមុខងារដូចតទៅ ៖

– ត្រូវទទួលប្រាក់ពន្ធដារ ដែលអ្នកស្រុកនៅក្នុងទី-ប្រជុំជនបានយកមកបង់ផ្ទាល់ ឬមួយប្រាក់ដែលចៅសង្កាត់នានាក្នុងចំណុះខ្លួននាំយកមកបង់ រួចហើយត្រូវប្រមូលប្រាក់ទាំងនេះទៅបង់បញ្ចូលក្នុងឃ្លាំងជាតិ ប្រចាំខេត្តក្នុងរយៈមួយខែម្ដង ។

– កាន់កាប់កិច្ចការទូទៅរបស់រាជការធំ ដែលបានបញ្ញត្តិឲ្យធ្វើ ព្រមទាំងមើលការខុសត្រូវគ្រប់មុខ ដើម្បីឲ្យអ្នកស្រុកបានសុខសាន្តត្រាណ និង បានសម្បូណ៌សប្បាយ ។

– ត្រូវជួយរកមធ្យោបាយយ៉ាងណាឲ្យបណ្ដាជននៅក្នុង

ស្រុកបានចំរើនខាងផលរបរគ្រប់មុខ ដូចជាការបែកចាយដីស្រែចំការឬដីភូមិ, ការរៀបចំឲ្យមានទំនប់ទឹក, ផ្លូវថ្នល់ឬគមនាគមន៍ទូទៅ ដើម្បីធ្វើសេដ្ឋកិច្ចបានផលល្អ រីកចំរើនឡើង ។ ខាងផ្លូវពាណិជ្ជកម្ម ការដឹកនាំទំនិញចេញចូលក្នុងស្រុក និងបង្កើតឲសហ្វាហកម្ម ក៏ត្រូវតែមានការទំនុកបំរុងពីអភិបាលស្រុកដែរ ។

— ត្រូវចេះជួយរិះរកមធ្យោបាយ ជួយពង្រីកខាងផ្លូវសង្គមកិច្ច ដូចជាមធ្យោបាយអប់រំអ្នកស្រុកឲ្យរស់នៅដោយចេះអនាម័យ មានការរៀបចំទីលំនៅ, ចំណីអាហារ, គ្រឿងប្រើប្រាស់ជាដើម ។ ជួយចាត់ការខាងព្យាបាលរោគ មានមន្ទីរពេទ្យ, ការអប់រំសុខភាព, ការចាក់ថ្នាំការពាររោគជាដើម ។ ទីបំផុត ត្រូវចេះជួយកសាងសាលារៀន គ្រប់ជាន់ថ្នាក់ ឲ្យអ្នកស្រុកបានរីកចំរើនខាងចំណេះប្រាជ្ញា ។

## ១- សេចក្ដីសង្ខេប.-

អភិបាលស្រុក និង សហការីត្រូវមានមុខងារដូចតទៅ ៖

ទទួលប្រាក់ពន្ធពីបណ្ដាក្រសួង ហើយប្រមូលប្រាក់ទាំងនេះទៅដាក់ឃ្លាំងជាតិ ក្នុងរយៈមួយខែម្ដង ។

- មើលការខុសត្រូវជាទូទៅ តំណាងកិច្ចការធំ ធ្វើឲ្យអ្នកស្រុកបានសុខរៀបរយតាមផ្លូវច្បាប់ ។
- ជួយរកមធ្យោបាយ កសាងសេដ្ឋកិច្ចក្នុងស្រុក ដូចជាការបង្កើនផលរបរ និងមានគមនាគមន៍ងាយស្រួល ។
- ជួយកសាងសាលារៀន មន្ទីរពេទ្យ និងអប់រំអនាម័យ ។

## គ- ការចោទសួរឡើងវិញ.-

- អភិបាលស្រុកនិងសហការី មានមុខងារធ្វើអ្វីខ្លះ ?
- ត្រូវយកប្រាក់ពន្ធទៅដាក់ឃ្លាំងក្នុង ១ ខែប៉ុន្មានដង ?
- អ្វីខ្លះដែលហៅថាសេដ្ឋកិច្ចក្នុងស្រុក ?
- ហេតុអ្វីបានជាត្រូវជួយខាងការកសាងសាលា និង មន្ទីរពេទ្យ ?
- ការអប់រំអនាម័យ ត្រូវធ្វើដូចម្ដេចខ្លះ ?
- អ្នក ដែលបានឃើញអភិបាលស្រុកទៅបំពេញមុខ ងារទាំងនេះទេ ?

## មេរៀនទី ១១ : របៀបចាត់ការក្នុងស្រុក

### ក- សេចក្ដីបរិយាយ .-

របៀបធ្វើការរាជការនៅក្នុងស្រុក គឺអភិបាលស្រុកជាធំជាងគេ ព្រោះជាតំណាងរាជរដ្ឋាភិបាល មើលខុស-ត្រូវលើភ្នាក់ងាររាជការក្រសួងដទៃ ៗ ទៀត ដែលមាននៅក្នុងស្រុក ដូចជាភ្នាក់ងារខាងកសិកម្ម, សុខាភិបាល, សិក្សាធិការ, សន្តិសុខជាតិ ។ល។ ចំនួននៃភ្នាក់ងារក្រសួងទាំងនេះ មិនមានកំណត់ចំនួនទេ ស្រេចតែសេចក្ដីត្រូវការរបស់ស្រុក ៗ ឯក្រសួងដែលមានចាត់ឲ្យមានភ្នាក់ងារទៅនៅប្រចាំស្រុកនោះ គឺក្រសួងណា ដែលមានការទាក់ទងផ្ទាល់ជាមួយប្រជារាស្ត្រ ដូចជាខាងសាធារណសុខាភិបាល ត្រូវមានមន្ទីរពេទ្យនៅក្នុងស្រុក; ខាងកសិកម្មត្រូវមានអ្នកកត់ត្រាដីស្រែ, មើលផលដំណាំដាំដុះ និង ការពារព្រៃឈើ, ខាងសិក្សាធិការ មាន

ការបង្ហាត់បង្រៀនយុវជន និង ការអប់រំមនុស្សខ្លៅ ៗ ដូច្នេះ ភ្នាក់ងាររាជការរបស់ក្រសួងផ្សេងៗ នេះ ជាអ្នកជួយធ្វើការ អភិបាលស្រុក តាមមុខងារនៃក្រសួងខ្លួន ឲ្យបានចំរើន និង ឲ្យបានសុខសាន្តក្នុងស្រុក ។

អភិបាលស្រុក ដោយមានសហការីផ្ទាល់ ដែលធ្វើការ នៅក្នុងសាលាស្រុក និងភ្នាក់ងារក្រសួងនានានេះ ជួយធ្វើការផង ត្រូវត្រួតត្រាការនៅលើចៅសង្កាត់ ដែលជាអ្នកកាន់កាប់សង្កាត់ផ្ទាល់ទៀត ។ ដូច្នេះ គឺជាសង្កាត់ទាំងឡាយនោះហើយ ដែលប្រជុំគ្នានៅក្រោមអំណាចដឹកនាំនៃអភិបាលស្រុកម្នាក់ ដែលមានសហការីដូចបានរាប់មកហើយ ជួយធ្វើការផង ។ អំណាចមន្ត្រីរាជការរួមគ្នានេះ ហៅថា "រាជការស្រុក" ។

## ១- គំនូសសំគាល់ជាន់ថ្នាក់ .-




## គ- ការចោទសួរឡើងវិញ .-

- សហការីផ្ទាល់របស់អភិបាលស្រុកមាននរណាខ្លះ ?

នរណាធំជាងនរណា ?

- ភ្នាក់ងារក្រសួងនានាឋិតនៅក្រោមអំណាចនរណា ?

- ដូចម្ដេចហៅថារាជការស្រុក ?

- រាជការស្រុក គាប់ត្រួតត្រាទៅលើនរណាទៀត ?

- ចូរគូរផែនទូសមួយ ដោយដាក់ព្រួញចង្អុល ពី របៀបជាន់ថ្នាក់អ្នកទាំងនេះផង ។

## មេរៀនទី ១២ : សិទ្ធិ និង ករណីយកិច្ចពលរដ្ឋ

### ក– សេចក្ដីបរិយាយ .–

សិទ្ធិ គឺអំណាចរបស់ពលរដ្ឋដែលត្រូវតែបានទទួលជាប្រយោជន៍របស់ខ្លួន គឺជាកិច្ចការត្រូវតែផ្ដល់ឲ្យជាចាំបាច់ ។

ពលរដ្ឋក្នុងស្រុកនីមួយ ៗ ត្រូវតែបានទទួលការចេះដឹង ដោយកិច្ចការចាត់ចែងការបង្ហាត់បង្រៀន និង អប់រំឲ្យចេះដឹងឡើង, ត្រូវតែបានសុខរៀបរយ ដោយកិច្ចការចាត់ប៉ូលីស ទាហានការពារសន្តិសុខក្នុងស្រុក និង ក្រៅស្រុក, ត្រូវតែបានសុខភាព ដោយកិច្ចការត្រូវបង្កើតឲ្យមានមន្ទីរការពាររោគ, ការពិនិត្យជម្ងឺ និង ថែជម្ងឺឲ្យបានសះស្បើយដូចធម្មតា ។ ក្រៅពីនេះ ត្រូវមានសិទ្ធិ ត្រូវបានទទួលជីវភាពសម្បូណ៌សប្បាយដូចជា ការរៀបចំទីលំនៅ ភូមិឋាន ផ្លូវថ្នល់ មានការទាក់ទងគមនាគមន៍ស្រួលងាយ និង ការបញ្ចេញមតិក្នុងការបោះឆ្នោតជាដើម ។

ក្រៅពីសិទ្ធិដែលខ្លួនត្រូវបានទទួលពីរាជការផងដែរ ពលរដ្ឋក៏ត្រូវតែជួយរាជការវិញជាការចាំបាច់ដែរ ដែលហៅថា "ករណីយកិច្ច" ។ ពលរដ្ឋត្រូវគោរពតាមអំណាចច្បាប់ឲ្យបានរៀបរយ, បើរាជការបញ្ញត្តយ៉ាងណាតាមលក្ខណៈច្បាប់ ពលរដ្ឋត្រូវតែប្រតិបត្តិ ដូចជារាជការតម្រូវឲ្យបង់ពន្ធ, ឲ្យគោរពច្បាប់បញ្ញត្តិក្នុងផ្លូវរក្សាសេចក្ដីសុខ, រក្សាទ្រព្យសម្បត្តិសាធារណៈ ដែលមាននៅក្នុងស្រុកដូចជាសាលា ផ្ទះពេទ្យ មន្ទីររាជការ ផ្លូវថ្នល់ ខ្សែលួស និង បង្គោលខ្សែលួស ។ ក្រៅពីនេះ ពលរដ្ឋត្រូវចេះចូលរួមធ្វើការហត្ថកម្មកសាងជាតិ ដែលអភិបាលស្រុកផ្ដើមធ្វើឡើង ។

## ១- សេចក្ដីសង្ខេប .–

សិទ្ធិគឺអំណាចពលរដ្ឋត្រូវតែបានទទួល មានការចេះដឹង គឺត្រូវបានរៀនសូត្រ, ត្រូវមានអ្នកថែនិងពិនិត្យសុខភាព, ត្រូវប្រកបជីវភាពសមរម្យ

ដោយមានភូមិស្រុកស្អាតបាត គមនាគមន៍ស្រួលងាយ និងការបញ្ចេញមតិតវ៉ា ឬបោះឆ្នោតបាន ។

ពលរដ្ឋត្រូវមានករណីយកិច្ច ជួយបង់ពន្ធជូនរាជការ, គោរពច្បាប់ផែនដី, ជួយការពារទ្រព្យសម្បត្តិសាធារណៈ និង ត្រូវចូលរួមក្នុងការងារហត្ថកម្មសានជាតិ ដែលអភិបាលស្រុកបានផ្ដើមធ្វើ ។

## គ- ការចោទសួរឡើងវិញ .—

- អ្វីដែលហៅថាសិទ្ធិ ?
- សិទ្ធិពលរដ្ឋ ត្រូវតែបានទទួលអ្វីខ្លះ ?
- ដូចម្ដេចហៅថាករណីយកិច្ច ?
- ពលរដ្ឋក្នុងស្រុកត្រូវមានករណីយកិច្ចម្ដេចខ្លះ ?
- ហេតុអ្វីបានជាត្រូវរួមក្នុងការហត្ថកម្មសានជាតិ ?
- អ្នកធ្លាប់ឃើញអ្នកស្រុកបំពេញករណីយកិច្ចឬទេ ?

## មេរៀនទី ១៣ : រៀនសារឡើងវិញ

### ក- សេចក្តីបរិយាយ .-

នៅក្នុងស្រុកនីមួយៗ មានមន្ត្រីរាជការ ហៅថាអភិបាលស្រុក នៅកាន់កាប់ការជំនួសរាជការគ្រប់ក្រសួង ដោយមានបុរាល័ក្ខ, លេខាធិការ, នៅជួយធ្វើការផ្ទាល់ក្នុងមន្ទីរចាត់ការប្រចាំស្រុក ហៅថា « សាលាស្រុក » ។ ក្រៅពីអ្នកធ្វើការផ្ទាល់ អភិបាលស្រុក បានជំនួយអំពីអ្នករាជការតំណាងក្រសួងផ្សេងៗ ដែលមុខក្រសួងនោះ បានចាត់ឲ្យទៅនៅកាន់ការផ្ទាល់ប្រចាំស្រុកផង ។ មន្ត្រីរាជការទាំងនេះ ត្រូវនៅក្រោមអំណាចរាជការស្រុក ដែលគេតែងឃើញមានជាចាំបាច់ គឺមន្ត្រីខាងគនរាជតម្រួត, សុខាភិបាល, សិក្សាធិការ, កសិកម្ម ក្រៅពីនេះ ស្រេចតែលើសេចក្តីត្រូវការរបស់ស្រុកនីមួយៗ ។

រាជការស្រុកមានមុខងារប្រមូលប្រាក់ពន្ធពីបណ្ដារាស្ត្រ, ជម្រះរឿងរ៉ាវ និង អត្រានុកូលដ្ឋានរបស់បណ្ដារាស្ត្រ ជាពិសេសគឺមើលការខុសត្រូវ រក្សាសេចក្ដីសុខរៀបរយ និង កសាងការចំរើនក្នុងស្រុក ៗ ចំណែកបណ្ដារាស្ត្រនៅក្នុងស្រុក ត្រូវមានសិទ្ធិក្នុងការការពារសេរីភាពរបស់ខ្លួនជាពលរដ្ឋ ដូចជាសិទ្ធិខាងបោះឆ្នោតបញ្ចេញមតិ, ខាងទទួលការចេះដឹង, ខាងរក្សាសន្តិសុខក្នុងស្រុកភូមិ និង ខាងរក្សាសុខុមាលភាព ព្រមទាំងសេចក្ដីឧបត្ថម្ភឲ្យបានចំរុងចំរើនក្នុងស្រុក ៗ មិនតែប៉ុណ្ណោះ ត្រូវមានករណីយកិច្ចក្នុងការបង់ពន្ធ, ក្នុងការជួយការពារស្រុកភូមិ និង ការពង្រីកសេចក្ដីចំរើនក្នុងស្រុករបស់ខ្លួន ៗ

## ១- សេចក្ដីសង្ខេប .-

មន្ត្រីរាជការគាត់កាប់ការ តំណាងរដ្ឋាភិបាលប្រចាំស្រុក ហៅថា "អភិបាលស្រុក" នៅធ្វើការ

ក្នុងមន្ទីរចាត់ការប្រចាំស្រុក ដែលហៅថា "សាលាស្រុក" ដោយមានបុគ្គល, លេខាធិការ និង មន្ត្រីតំណាងក្រសួងផ្សេងៗទៀតជួយធ្វើការផង ។ មុខងាររាជការស្រុកគឺទទួលប្រាក់ពន្ធ, ជួយកសាងជីវភាពអ្នកស្រុកឲ្យបានចំរើន ។ ចំណែក បណ្ដាជនក្នុងស្រុកវិញ ត្រូវមានសិទ្ធិក្នុងការបោះឆ្នោត, ក្នុងការទទួលចំណេះវិជ្ជា និង ការបានសុខរៀបរយ ។ ក្រៅពីនេះ ត្រូវមានករណីយកិច្ចបង់ពន្ធជូនរាជការ និង ជួយធ្វើការពង្រីកជីវភាពក្នុងស្រុក ។

## គ- ការចោទសួរឡើងវិញ .–

– មន្ត្រីទៅកាន់ការក្នុងស្រុក ហៅថាអ្វី ?

– មានអ្នកណាខ្លះជួយធ្វើការជាមួយផង ?

– បណ្ដារាស្ត្រក្នុងស្រុកមានសិទ្ធិបែបណាខ្លះ ?

– និងមានករណីយកិច្ចត្រូវធ្វើអ្វីខ្លះ ?

# PROGRAMME

## 3ème TRIMESTRE

(Mai, Juin, Juillet)

— L'Office Royal de Coopération.

— Etudier les particularités du Srok et voir en même temps ce qui doit être fait pour en redresser le niveau social et économique.

— Revision générale.

## ត្រីមាសទី ៣ :

ខែ ឧសភា - មិថុនា - កញ្ញា

### មេរៀនទី ១៤ : រាជសហករណ៍(១)

## ក- សេចក្ដីអធិប្បាយ .–

*ដែលហៅថា "រាជសហករណ៍" គឺជាអង្គការមួយ ដែលសង្គមរាស្ត្រនិយមបង្កើតឡើង ដើម្បីជួយដោះស្រាយ បញ្ហាជីវភាពបណ្ដាជនខ្មែរ ក្នុងការលក់និងការទិញនូវគ្រឿង បរិភោគនិងគ្រឿងប្រើប្រាស់ ព្រមទាំងផលដំណាំដែលកើត មានឡើងនៅក្នុងស្រុកភូមិ ។*

---

១– សូមបញ្ជាក់ថា មេរៀនពី "រាជសហករណ៍" នេះ ជាសេចក្ដីសង្ខេបទេ ព្រោះកម្មវិធីតម្រូវឲ្យតែសិស្សស្គាល់ឈ្មោះសិនតែប៉ុណ្ណោះ លុះដល់ថ្នាក់ទី ៨ ទើបបានត្រូវរៀនឲ្យពិស្ដារ ។

ពាក្យថា "រាជសហករណ៍" មកពីភាសាបាលីមាន

បំព្យាង្គគឺ ៖

រាជ = ស្តេច + សហ = រួម + ករណ = អំពើ ។

រួមសេចក្តីទៅ ពាក្យនេះបានន័យថា អំពើដែលកើត

ឡើងដោយសាររួមកម្លាំងគ្នា នៅក្នុងព្រះរាជអាណាចក្រ ។

បានជាមានឈ្មោះដូច្នេះ ព្រោះរាជសហករណ៍ មានដំណើរ

ការណ៍ដូច្នេះ ៖

ការកើតឡើងដំបូង គឺមានអ្នកស្រុកជាច្រើននាក់រួម

គំនិតគ្នា ចូលប្រាក់ធ្វើជាក្រុមហ៊ុនមួយឲ្យបានដើមទុនច្រើន

ហើយយកប្រាក់នោះទៅទិញរបស់បរិភោគ របស់ប្រើប្រាស់

យកមកលក់បែកឲ្យអ្នកស្រុក ដែលបានចូលហ៊ុននោះវិញ

ដោយតម្លៃថោក ព្រោះយកចំណេញតែបន្តិចបន្តួច ។ ក្រៅ

ពីនេះ គេយកប្រាក់ហ៊ុននេះទិញផលពីអ្នកស្រុក ទុកលក់

ឲ្យឈ្មួញក្រៅឬលក់ឲ្យក្រុមហ៊ុនណាធំៗ កុំឲ្យឈ្មួញបន្ថោក

ថ្ងៃបាន ។ កាលណាបានចំណេញ ត្រូវយកប្រាក់ចំណេញនោះ មកចែកឲ្យអ្នកចូលហ៊ុន តាមភាគដើមទុន ។ ដើម្បីចាត់ចែងការ គេក៏មានអ្នកគ្រប់គ្រង ដែលគេបោះឆ្នោតរើស ក្នុងរយៈពេល ១ ឆ្នាំម្តង ។

## ១- សេចក្តីសង្ខេប :-

ពាក្យថា "រាជសហករណ៍" បានន័យថា "អំពើដែលគេធ្វើឡើងដោយរួមកម្លាំងគ្នា នៅក្នុងព្រះរាជាណាចក្រ" ។ បានសេចក្តីថា អង្គការនេះកើតពីអ្នកស្រុកចូលរួមប្រាក់គ្នាជាក្រុមហ៊ុនមួយ យកដើមទុនទៅទិញរបស់មកលក់ឲ្យអ្នកស្រុក ឲ្យបានតម្លៃថោក និងទិញផលពីអ្នកស្រុកឲ្យបានថ្លៃច្រើន ។ អ្នកគ្រប់គ្រងកាន់កាប់ការ ត្រូវគេជ្រើសតាំងដោយបោះឆ្នោតក្នុងរយៈមួយឆ្នាំម្តង ។

## គ- ការលោទសួរឡើងវិញ.-

- ពាក្យថា ភាពសហករណ៍ ប្រែថាម៉េច ?
- កើតជាអង្គការនេះ ដោយសារអ្វី ?

  អ្នកណាត្រូវបានជាអ្នកកាន់កាប់ការនេះ ?
- នៅស្រុក-ភូមិរបស់អ្នក មានសហករណ៍ឬទេ ?
- អ្នកធ្លាប់ចូលទៅសហករណ៍ មានឃើញលក់អ្វីខ្លះ ?

## មេរៀនទី ១៥ : អំពីរាជសហករណ៍ (ក)

### ក – សេចក្ដីបរិយាយ .–

របៀបរៀបចំនៃសហករណ៍ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដែលមានប្រធាន អនុប្រធាន លេខាធិការ ហេរញ្ញិក និង ទីប្រឹក្សា រួបរួមគ្នា ។ អ្នកទាំងអស់នេះ តែងតាំងឡើងដោយការបោះឆ្នោត គឺសមាជិកទាំងអស់ដែលបានចូលហ៊ុនក្នុងសហករណ៍ មករួមប្រជុំគ្នា និង បោះឆ្នោតជ្រើសរើសអ្នកណាដែលជាទីទុកចិត្ត ឲ្យធ្វើជាក្រុមប្រឹក្សាភិបាលធ្វើការជំនួសខ្លួន ។ ការជ្រើសតាំងនេះ ត្រូវធ្វើក្នុងរយៈពេលមួយឆ្នាំម្ដង ។

ប្រាក់ដើមដែលអ្នកស្រុកចូលហ៊ុនគ្នានេះ បើមិនបានគ្រប់គ្រាន់ គេអាចទៅសុំឲ្យអគ្គការរាជសហករណ៍នៅប្រចាំខែត្រ ឬមន្ទីររាជសហករណ៍ធំនៅក្រុងភ្នំពេញជួយផ្ដល់បន្ថែម ។ ព្រោះថា សហករណ៍ប្រចាំភូមិនេះ គេហៅថា "សាខា"

ឬឲ្យឈ្មោះមួយថា "សហករណ៍យើង" សុទ្ធសឹងតែធ្វើឡើងនៅក្រោមអំណាចរាជសហករណ៍ធំ ទាំងអស់គ្នា ។

សិស្សានុសិស្សគាបរួបរួមគ្នា ធ្វើជាសហករណ៍មួយក្នុងសាលាខ្លួនក៏បាន គឺបូលប្រាក់គ្នាបន្តិចម្នាក់ ហើយជ្រើសរើសសិស្សណា ឬលោកគ្រូណាឲ្យធ្វើអ្នកចាត់ការ ដែលយើងហៅថា "ក្រុមប្រឹក្សាភិបាល" មួយឡើង ៗ យើងប្រមូលប្រាក់ដើមនោះ ទៅទិញរបស់សំរាប់សិស្សប្រើប្រាស់ ដូចជាខ្មៅដៃ, ស្លាបប៉ាកកា, សៀវភៅសរសេរ, សៀវភៅរៀនអាន ឬសៀវភៅអ្វីដទៃទៀត និងប្រដាប់ប្រដាសម្រាប់ធ្វើកីឡា ៗ របស់ទាំងនោះលក់ឲ្យសិស្សវិញ និងយកចំណេញតិចតួចទុកក្នុងហិប សម្រាប់ចែកចំណេញ នៅពេលដាច់ឆ្នាំសិក្សាម្ដង ៗ ។

## ខ - សេចក្ដីសង្ខេប .–

អ្នកគ្រប់គ្រងសហករណ៍ ហៅថា "គ្រុមប្រឹក្សាភិបាល" ដែលសមាជិកទាំងអស់ បោះឆ្នោតទុកចិត្តតែងតាំងឡើង សំរាប់ពេលមួយឆ្នាំ ៗ សហករណ៍ទាំងអស់ តែងមានការទាក់ទងនឹងភជសហករណ៍ប្រចាំខេត្ត ឬភជសហករណ៍ធំនៅភ្នំពេញ ៗ បើប្រាក់ដើមមិនបានគ្រប់គ្រាន់ សហករណ៍ទាំងនឹងជួយផ្ដល់ឲ្យ ៗ

សិស្សអាចរួមគ្នាធ្វើជាសហករណ៍បានដែរ ដើម្បីលក់ប្រដាប់ប្រដាសម្រាប់សិក្សា និងសម្រាប់ហាត់កីឡា ៗ

## គ - ការចោទសួរឡើងវិញ.–

– អ្នកគ្រប់គ្រងសហករណ៍ គេហៅថាអ្វី ?

- អ្នកទាំងនេះតែងតាំងឡើង តាមរបៀបណា ?

- សហករណ៍ទាំងនេះ ត្រូវមានការទាក់ទងទៅសហ-ករណ៍ធំឬទេ ? មានប្រយោជន៍អ្វី ?

- សិស្សអាចធ្វើសហករណ៍បាន តាមរបៀបណា ?

## មេរៀនទី ១៦: ពិនិត្យពីលក្ខណៈស្រុក-ភូមិ (១)

### ក– សេចក្តីបរិយាយ .–

នៅក្នុងភូមិយើងឬថានៅក្នុងស្រុកយើងទាំងមូល អ្នកស្រុករស់នៅក្នុងរបរកសិកម្មជាចំនួនច្រើនជាងគេ គឺមានធ្វើស្រែ, ធ្វើចំការ ដាំពោត សណ្តែក កប្បាស ថ្នាំជក់ ស្ករ ល្ង ម្រេច ។ល។ ផលសំខាន់មួយពិសេសគឺកៅស៊ូ ។ ក្រៅពីដំណាំសំខាន់ៗ ដូចបានរាប់មកហើយនេះ នៅមានដំណាំកយរងច្រើនទៀត ដែលអាចឲ្យផលដល់អ្នកស្រុកជា

១– សូមបញ្ជាក់ចំពោះលោកគ្រូអ្នកគ្រូថា មេរៀនអំពីការពិនិត្យលក្ខណៈស្រុក-ភូមិនេះ អាស្រ័យនៅតាមភូមិ-ស្រុកផ្ទាល់ ដែលជាទីតាំងសាលានោះ បើសាលាស្ថិតនៅក្នុងភូមិធ្វើចំការ តោងរាប់រៀបពីរឿងចំការ បើនៅស្រុកស្រែក៏និយាយតែពីរឿងស្រែ តែបើនៅស្រុកផ្សារ ក៏តោងនិយាយពីរបរពាណិជ្ជកម្ម ហើយនឹងបន្ថែមរបរអ្វីជាអម្រស់អម្រែងផង ។ ដូច្នេះ មេរៀនដែលមានតទៅនេះ គ្រាន់តែបង្ហាញជាគំរូប៉ុណ្ណោះ ។

ច្រើនណាស់ដែរ ដូចជាទឹកត្នោតសំរាប់ធ្វើស្ករ បេក ក្រូច សារ៉ាវ ដូរេន ម្នាស់ ល្មុត ទៀប ខ្នុរ ល្ហុង ឬ របស់ធ្វើជាបន្លែមាន ខ្ញី, ស្ពៃ សាឡាត់ ខ្ទឹម ម្ទេស ជីរ, . . . ។

ក្រៅពីរបរទាំងនេះ អ្នកស្រុកនៅមានការនេសាទ ជារបរប្រចាំភូមិសំខាន់ណាស់ដែរ គឺអ្នកនៅជិតអាងមាត់ទន្លេសាប យកទន្លេសាបធ្វើជាកន្លែងប្រកបរបរនេះ ឯអ្នកនៅតាមមាត់សមុទ្រ ក៏មានការនេសាទក្នុងទឹកសមុទ្រ អ្នកនៅតាមដងទន្លេ មានទន្លេធំ ទន្លេបាសាក់ ដៃទន្លេសាប ឬអ្នកនៅតាមមាត់ព្រែកសំខាន់ៗ ក៏ប្រកបការនេសាទនៅតាមទីនោះដែរ ។ ចំណែកអ្នកនៅតាមស្រុកស្រែវិញ គេមានរបរនេសាទតិចតួចណាស់ គឺមានតែធ្វើនៅតាមបឹងបួ ឬថ្លុកត្រពាំងដែលរីងហួតនៅរដូវប្រាំង ។

ទាំងអស់នេះហើយ ជាលក្ខណៈពិសេសនៃមុខរបរអ្នកស្រុកខ្មែរ ។

## ខ- សេចក្ដីសង្ខេប .-

អ្នកស្រុក-ភូមិខ្ញុំយើងមានរបរធំបំផុតគឺកសិ-កម្មមានធ្វើស្រែយកស្រូវ ធ្វើចំការពោត, សណ្ដែកដី, កប្បាស, ថ្នាំជក់ជាសំខាន់ៗ ក្រៅពីនេះមានដំណាំស៊ីផ្លែ ដូចជាចេក, ម្នាស់, សាវម៉ាវ, មង្ឃុតទៀប, មៀន, ក្រូច, ធូរេន, ជាដើម និងមានដំណាំជាបន្លែច្រើនទៀត ដូចជា ម្ទេស, ខ្ញី, ត្រប់, ស្ពៃ, សាឡាត់, ខ្ទឹម ។ល។ មានរបរមួយទៀតមានជាទូទៅដែរ គឺការនេសាទ ដែលអ្នកស្រុកអាចធ្វើបាន នៅស្ទើរគ្រប់ទីកន្លែង ហើយនិងធ្វើបាននៅគ្រប់រដូវផង ។

## គ- ការចោទសួរឡើងវិញ .-

- របរសំខាន់នៅស្រុកភូមិយើងគឺអ្វី ?

ដំណាំសំខាន់មានអ្វីខ្លះ ? និងដំណាំបន្ទាប់បន្សំមាន
អ្វីខ្លះ ?

– គេធ្វើនេសាទបាននៅឯណាខ្លះ ?

– អ្នកបានឃើញគេធ្វើស្រែប្រាំងទេ? តើត្រូវធ្វើដូចម្ដេចខ្លះ?

– បើគ្មានដំណាំកសិករទេ យើងមានការខ្វះខាតទេ ?

## មេរៀនទី ១៧ : មធ្យោបាយកសាងជីវភាពស្រុក

### ក- សេចក្ដីបរិយាយ .-

ដោយសារប្រទេសស្រុកយើង មានរបរកសិកម្មជារបរធំ ម្ល៉ោះហើយ បើចង់ជួយកសាងភូមិ-ស្រុកនេះ ឲ្យសុខប្រកប នឹងជីវភាពថ្កុំថ្កើង តោងគិតគូរពីជួយពង្រីកកសិកម្ម ដូចជាការរៀបចំដីស្រែឲ្យមានប្រឡាយទឹក អាចផ្ដល់ឲ្យធ្វើស្រែបានស្រួល កុំឲ្យគិតតែពឹងចាំតែទឹកភ្លៀង ដ្បិតទឹកភ្លៀងមិនទៀងទេ ជួនច្រើនពេក ជួនតិចពេក អាចធ្វើដំណាំដោយជន់លិចរលួយអស់ ហើយឲ្យរាំងហួតស្លាប់ដំណាំអស់ក៏មាន ។ ចំពោះដីណា ដែលពុំសូវមានជីជាតិ ត្រូវតែចេះប្រើជីផ្សំជាមួយផង ព្រមទាំងត្រូវរៀនឲ្យចេះនូវរបៀបប្រើជីនោះទៀត ។ ក្នុងការប្រកបរបរកសិកម្មទៅពេលបច្ចុប្បន្ន គួរតែមានគ្រឿងចក្រគ្រឿងយន្ត ប្រើជួយកម្លាំងមនុស្សកម្លាំងសត្វគោក្របី

ផង ជួបផាក្នុងការឃ្លួរកាស់ ក្នុងការដឹកនាំជាដើម ។

ព្រះបានផលហើយ គេនឹងគិតគំពីផ្លូវជំនួញ គឺធ្វើយ៉ាងណាឲ្យផលតាំងនោះលក់បានថ្លៃ និងមានអ្នកទិញគ្រប់គ្រាន់ កុំឲ្យសល់ចោល ។ ឯប្រាក់កាសធ្វើសោហ៊ុយក្នុងការប្រកបរបរនេះ ក៏ត្រូវមានផ្តល់ឲ្យបានស្រួលផង កុំឲ្យអ្នកកសិករយើងពិបាកទៅខ្ចីលុយពីថៅកែ ដែលគេនឹងយកចំណេញលើសលុបលើកម្លាំងកសិករ ។ ក្នុងគំនិតដោះស្រាយបញ្ហាទាំងនេះ បានជាត្រូវមានសហករណ៍ប្រចាំភូមិ ស្រុករបស់យើង ។

ក្រៅពីខាងមុខរបរអ្នកស្រុក គេនឹងមានការបណ្តុះបណ្តាលឲ្យអ្នកស្រុក មានបញ្ញាតម្រិះវិជ្ជាផង ។ ត្រង់នេះហើយដែលគេត្រូវតែបង្កើតសាលារៀន នៅប្រចាំភូមិ-ស្រុកដោយខានមិនបាន ។ មួយទៀតត្រូវមានសាមគ្គីធម៌រវាងអ្នកស្រុក ម៉្លោះហើយត្រូវបេះដូងគ្នាធ្វើបុណ្យទាន សង់ស្ពានលើកថ្នល់ បង្កើតពិគ្គសាមគ្គី ។

## ១- សេចក្ដីសង្ខេប .-

មធ្យោបាយជួយកសាងស្រុក-ភូមិយើងឲ្យបានថ្កុំថ្កើងនោះ តោងគិតយ៉ាងណាឲ្យរបរកសិកម្មបានចំរើន ដូចជាការធ្វើឲ្យមានទឹកដាក់ស្រែ កុំបាច់ពឹងលើទឹកភ្លៀង, មានដីដាក់ជីឲ្យមានជីជាតិកើនផលច្រើន និងប្រើកំឡាំងគ្រឿងចក្រជំនួសកំឡាំងមនុស្សនិងគោក្របីផងៗ បន្ទាប់មក ត្រូវគិតខាងផ្លូវលក់ដូរ ផលកសិកម្មនោះឲ្យបានថ្លៃ ហើយជៀសវាងកុំឲ្យឈ្មួញយកចំណេញ លើអ្នកស្រុកច្រើនពេកៗ ត្រង់នេះត្រូវតែមានសហករណ៍ធ្វើជាអ្នកដោះស្រាយ, មួយទៀតត្រូវបណ្ដុះវិជ្ជាឲ្យអ្នកស្រុក ដោយបង្កើតសាលារៀនជាការចាំបាច់ ព្រមទាំងបេះរបួមអ្នកស្រុកឲ្យចេះធ្វើបុណ្យ

ទាន  រួមកំឡាំងសង់ស្ពានលើកថ្នល់ជាការបណ្ដុះ
សាមគ្គីរវាងអ្នកស្រុក ។

## គ- ការចោទសួរឡើងវិញ .–

– មធ្យោបាយកសាងស្រុកភូមិឲ្យចំរើនគោងធ្វើម្ដេច ?

– ហេតុអ្វីបានជាត្រូវជួយពង្រីករបរកសិកម្ម ?

– គោងធ្វើដូចម្ដេចឲ្យអ្នកស្រុកចេះដឹង ?

– មធ្យោបាយធ្វើឲ្យអ្នកស្រុកមានសាមគ្គីគ្នាត្រូវធ្វើម្ដេច?

– អ្នកធ្លាប់បានឃើញគេប្រើគ្រឿងចក្រធ្វើស្រែទេ ?

– ចូរនិយាយពីរបៀបសង់ស្ពាន-លើកថ្នល់ក្នុងភូមិអ្នក ?

តម្កល់ទុកតាមច្បាប់
លេខ ៤៣៤ ចុះថ្ងៃទី ២៨ - ៨ - ៦៧
បោះពុម្ពលើកទី ១ ចំនួន ២០០០ ក្បាល

បណ្ណា

រោងពុម្ព រស្មី

តម្លៃ ១៥ រៀល